# ក

# មាតិកា

## I.~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៤-៦-២០០៧ | -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៩២ ស្តីពី :<br>១-ត្រូវបានបញ្ចប់មុខតំណែង ឯកឧត្តម **ហ៊ី សាំងអេង** ពីអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា<br>**២**-ត្រូវបានតែងតាំង ឯកឧត្តម **ពេជ ឌុន** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ជំនួសឯកឧត្តម **ហ៊ី សាំងអេង** ដែលត្រូវបាន បញ្ចប់មុខតំណែង | ៤៥៩៦ |
| ២៤-៦-២០០៧ | -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៩៣ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូននាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៧ រូប | ៤៥៩៧ |
| ២៥-៦-២០០៧ | -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៩៤ ស្តីពីការធ្វើវិសោធនកម្មព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៦ ដោយកែសម្រួលផ្ទៃដីតំបន់ដែនជម្រកសត្វព្រៃភ្នំណាមល្យើរ ពីផ្ទៃដីសរុបទំហំ ៤៧.៥០០ ហិកតា មកនៅត្រឹម ៣៩.៤៥០ ហិកតា | ៤៥៩៨ |
| ២៥-៦-២០០៧ | -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៩៥ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ២៤ រូប | ៤៦០១ |
| ២៦-៦-២០០៧ | -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៩៦ ស្តីពីការតែងតាំងឯកឧត្តម **ឯក សំអុល** ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិបីឆ្នាំ លើកទី ៤ ( ឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១០) | ៤៦០៣ |
| ២៦-៦-២០០៧ | -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៩៧ ស្តីពីការផ្ទេរក្របខ័ណ្ឌលោក **ម៉ែប្រុខ សាធុន** ពីអនុមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ទៅជាអនុមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលនៅក្រសួងផែនការ | ៤៦០៤ |

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ២៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៧៥ អនក្រ.តត ស្តីពីការតែងតាំងសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា | ៤៦០៥ |
| ២៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៧៦ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៤៦០៦ |
| ២៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៧៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៤៦០៨ |
| ២៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៧៨ អនក្រ.តត ស្តីពីការកែសម្រួលមុខតំណែង និងតែងតាំងមន្ត្រី រាជការ | ៤៦០៩ |
| ២៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៦១១ |
| ២៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៦១២ |
| ២៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៨១ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ៤៦១៣ |
| ២៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៨២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៤៦១៤ |
| ២៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៨៣ អនក្រ.តត ស្តីពីការកែសម្រួលសមាសភាព ក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា | ៤៦១៥ |


## III. ការងារបណ្ដាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សេចក្តីជូនដំណឹង


| | | |
|---|---|---|
| ០៦-៦-២០០៧ | -សេចក្តីជូនដំណឹងលេខ ០១០ សហវ.ប្រក.ពដ ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីមិនបានប្រើប្រាស់ | ៤៦១៧ |


### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស


| | | |
|---|---|---|
| ២៥-៦-២០០៧ | -ប្រកាសលេខ ៦០៨ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សាន់នី អ៊ីបភែរេល មេនញូហ្វេកឈឺរីង បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " សាន់នី អ៊ីបភែរេល មេនញូហ្វេកឈឺរីង " | ៤៦១៩ |

២៥-៦-២០០៧ -ប្រកាសលេខ ៦០៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន គ ឈ ហ្សេស៊ិន សហគ្រាស បង្កើតរោងចក្រ "ផលិតសសរគ្រឹះបេតុង" ដែលមានឈ្មោះថា "គ ឈ ហ្សេស៊ិន សហគ្រាស សាខាទី ១" ៤៦២១

២៥-៦-២០០៧ -ប្រកាសលេខ ៦១០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន (ខេមបូឌា) បាយអូ-ថេក ឌីវេឡុបមេន បង្កើតរោងចក្រ "ផលិតប្រេងជីវឥន្ធនៈ" ដែលមានឈ្មោះថា "(ខេមបូឌា) បាយអូ-ថេក ឌីវេឡុបមេន" ៤៦២៣


## ៣. ឯកសារនៃការិយាល័យរដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សារាចរណែនាំ


២៦-៦-២០០៧ -សារាចរណែនាំលេខ ០១៧ អបស/មត ស្តីពីការបង្កើនការលើកទឹកចិត្តចំពោះឆ្មប ដោយបង្កើនប្រាក់ឧបត្ថម្ភជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ ៤៦២៥


## ៤. ឯកសារនៃការិយាល័យរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

### សេចក្តីសំរេច


២៧-៦-២០០៧ -សេចក្តីសំរេចលេខ ១៣២ សសរ.ធទឧ ស្តីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ៤៦២៧


## ៥. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### សេចក្តីសំរេច


២២-៦-២០០៧ -សេចក្តីសំរេចលេខ ២៦៥/០៧ គ.ជ.ប សសរ ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រ **គណបក្សប្រជាជនកម្ពុជា** ចេញពីមណ្ឌលខេត្ត ព្រៃវែង ៤៦២៩

២២-៦-២០០៧ -សេចក្តីសំរេចលេខ ២៦៦/០៧ គ.ជ.ប សសរ ស្តីពីការប្រកាសទទួលស្គាល់ឯកឧត្តម **សុខ សាយ** បេក្ខជនតំណាងរាស្ត្រពេញសិទ្ធិលំដាប់ទី ១០ របស់ **គណបក្សប្រជាជន**កម្ពុជា នៅមណ្ឌលខេត្ត ព្រៃវែង ៤៦៣០

២៧-៦-២០០៧ -សេចក្តីសំរេចលេខ ២៦៧/០៧ គ.ជ.ប សសរ ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រ **គណបក្ស សម រង្ស៊ី** ចេញពីមណ្ឌលរាជធានីភ្នំពេញ ក្រុង ភ្នំពេញ ៤៦៣១

២៧-៦-២០០៧ -សេចក្តីសំរេចលេខ ២៦៨/០៧ ក.ជ.ប សសរ ស្តីពីការប្រកាសទទួលស្គាល់ឯកឧត្តម **នូ សុវត្ថិ** បេក្ខជនតំណាងរាស្ត្រពេញសិទ្ធិលំដាប់ទី ០៨ របស់ **គណបក្ស សម រង្ស៊ី** នៅមណ្ឌលក្រុង ភ្នំពេញ ៤៦៣២

## ៦. និស្ស័យការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៧-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កែវ ថាវ អ៊ីមផត អិចផត & ឌីវេឡុបមេន (ខេ.ធី.អេ)** ៤៦៣៣

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថាវ សាន អេន ធើត្រាយ** ៤៦៣៥

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈាង ហួត** ៤៦៣៧

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេតក្ខ (ខេមបូឌា) ខូ អិលធីឌី** ៤៦៣៩

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦១៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុង ច័យ ខូ អិលធីឌី** ៤៦៤១

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហួរ អ៊ី.អេស.អ៊ិនវេស មេនគ្រុប** ៤៦៤២

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីខន** ៤៦៤៤

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជុង ហៀង ខម តេនី លីមីធីត** ៤៦៤៦

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នីអូខម អាយ អេស ភី លីមីធីត** ៤៦៤៨

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូឌែន ថេកណូឡូជី ឡូជីស្ទីក** ៤៦៥០

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តុប តុខហោខ អ៊ីមផត អិចផត** ៤៦៥២

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូសេដន់** ៤៦៥៤

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.អិល.ភី អ៊ីមផត អិចផត** ៤៦៥៦

០៨-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៦៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កៅ សុវណ្ណ អ៊ីមផត អិចផត** ៤៦៥៨

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៥២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថបិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម ហ៊ូ តាំងអេង ពីអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**មាត្រា ២:** ត្រូវបានតែងតាំងឯកឧត្តម ពេជ ឌុន ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ជំនួសឯកឧត្តម ហ៊ូ តាំងអេង ដែលត្រូវបានបញ្ចប់មុខតំណែង ។

**មាត្រា ៣:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧៧.០៧០៦.២៦៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧*

លេខ ២៥៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថបិយជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ត្រី ឈុម រតនា អត្តលេខ ០០១៨៨១
២-ឧត្តមសេនីយ៍ត្រី យស់ សារិទ្ធ អត្តលេខ ០០២៥៧០
៣-ឧត្តមសេនីយ៍ត្រី ស៊ឹម សុន្ទ អត្តលេខ ០០២៣៤៩
៤-ឧត្តមសេនីយ៍ត្រី គន់ ហេង អត្តលេខ ០០៣៣២៧
៥-ឧត្តមសេនីយ៍ត្រី ឡុង ម៉េង អត្តលេខ ០១១៨០៨
៦-ឧត្តមសេនីយ៍ត្រី ទីសុន្ទ សំបុះ អត្តលេខ ០០០៦៦៨
៧-ឧត្តមសេនីយ៍ត្រី លន់ សុនី អត្តលេខ ០១៩៧២០

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ.ល.០៧០៦.២៦៨

លេខ:៤៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

សុខ ជិនដា

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា១. –**

ត្រូវបានធ្វើវិសោធនកម្មព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា២ ចំណុចទី២ លេខរៀងទី១៦ ដោយកែសម្រួលផ្ទៃដីតំបន់ដែនជម្រកសត្វព្រៃភ្នំណាមល្យើរ ពីផ្ទៃដីសរុបទំហំ **៤៧.៥០០ហិកតា** មកនៅត្រឹម **<u>៣៩.៤៥០ហិកតា</u>**។ ដូច្នេះផ្ទៃដីដែលត្រូវកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំណាមល្យើរមានទំហំ **៨.០៥០ហិកតា**។ ផែនទីព្រំប្រទល់ និងនិយាមកា នៃតំបន់ដែនជម្រកសត្វព្រៃភ្នំណាមល្យើរ ដែលបានកែប្រែថ្មី មានក្នុងឧបសម្ព័ន្ធ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា២. –**

ធ្វើការកែសម្រួលផ្ទៃដីទំហំ **៨.០៥០ហិកតា** ដែលបានធ្វើវិសោធនកម្មកាត់ចេញពីផ្ទៃដី នៃដែនជម្រកសត្វព្រៃភ្នំណាមលៀរ ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី ពីដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋវិញ។

**មាត្រា៣. –**

សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា៤. –**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៧០៦.២៦៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧*

លេខៈ ២៥៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០០៧

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ឃុន ជិនកេន**

ឧបសម្ព័ន្ធ

## ផែនទី ដែនជំរកសត្វព្រៃ ភ្នំណាមលៀរ




| | | | |
|---|---|---|---|
| 1 | A | [illegible] | [illegible] |
| 2 | B | 769607 | [illegible] |
| 3 | C | 769608 | [illegible] |
| 4 | D | 770613 | [illegible] |
| 5 | E | 770663 | [illegible] |
| 6 | F | [illegible] | [illegible] |
| 7 | G | 770013 | [illegible] |
| 8 | H | 766505 | [illegible] |
| 9 | I | 777149 | 1372000 |
| 10 | J | 773346 | 1372000 |
| 11 | K | 773329 | 1380000 |
| 12 | L | 774000 | 1380000 |
| 13 | M | 774000 | 1382000 |
| 14 | N | 780671 | 1382000 |

សញ្ញាសំគាល់

ព្រំប្រទល់ដែនជំរកសត្វព្រៃ ភ្នំណាមលៀរ

Phnom Nam Lyr W.S. Boundary

ផ្ទៃដីដែលកាត់ចេញមានទំហំ ៨០៩០ ហិកតា

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ឯក **មាស សុខុន** អត្តលេខ ០០១២១៩
២-វរសេនីយ៍ឯក **ព្រាប លីណា** អត្តលេខ ០០១០៩៩
៣-វរសេនីយ៍ឯក **ឯល ចន្ថាផន** អត្តលេខ ០០៤០១៦
៤-វរសេនីយ៍ឯក **ឃួន សារិន្ត** អត្តលេខ ០០២៣៩៩
៥-វរសេនីយ៍ឯក **ជា លីស្រ៊ុន** អត្តលេខ ០១២១៧៤
៦-វរសេនីយ៍ឯក **សុខ ចន្ថា** អត្តលេខ ០០៤០៦៧
៧-វរសេនីយ៍ឯក **ឈួន គឹមសាន** អត្តលេខ ០០៤០១៩
៨-វរសេនីយ៍ឯក **អ៊ុង សារីគុត្ត** អត្តលេខ ០១១៨១៣
៩-វរសេនីយ៍ឯក **លឹម ប៊ុនធី** អត្តលេខ ០០៤០១៤

១០-វរសេនីយ៍ឯក ម៉ើន រុន អត្តលេខ ០០៣៧៧១

១១-វរសេនីយ៍ឯក អ៊ុន នុត អត្តលេខ ០១១៦៤៨

១២-វរសេនីយ៍ឯក នយ មុត អត្តលេខ ០១១៦៦៨

១៣-វរសេនីយ៍ឯក គីម រិទ្ធិ អត្តលេខ ០០៤៤៦៥

១៤-វរសេនីយ៍ឯក អ៊ុក អ៊ុន អត្តលេខ ០០៣៣២៩

១៥-វរសេនីយ៍ឯក ម៉ើន ចំន្ទ អត្តលេខ ០០១៦២៩

១៦-វរសេនីយ៍ឯក ស្រួល សុជា អត្តលេខ ០១១៧៧៨

១៧-វរសេនីយ៍ឯក ម៉ើន សុខ អត្តលេខ ០០៤០៩៥

១៨-វរសេនីយ៍ឯក ហាម ឫទ្ធី អត្តលេខ ០០៥១៧៩

១៩-វរសេនីយ៍ឯក ខួន ហុខ អត្តលេខ ០១១៦៣៧

២០-វរសេនីយ៍ឯក ឡូ មិថុនា អត្តលេខ ០០២៤១២

២១-វរសេនីយ៍ឯក សំ សៀន អត្តលេខ ០០៣៣៤៣

២២-វរសេនីយ៍ឯក សុខ សារ អត្តលេខ ០០៨៣៤៨

២៣-វរសេនីយ៍ឯក ស៊ី ហូហ៊ុយ អត្តលេខ ០០២៣៥៤

២៤-វរសេនីយ៍ឯក ម៉ើន សារ៉ត់ អត្តលេខ ០០៤៥៨១

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០៧០៦.២៧០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧

លេខ:២៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ធានដារ៉ាវង្ស អធិបតីនៃសម័យប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិបីឆ្នាំ លើកទី៤ ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១០

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ឯក សំអុល ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិបីឆ្នាំ លើកទី៤ ( ឆ្នាំ២០០៧ ដល់ ឆ្នាំ២០១០ ) ។

**មាត្រា ២ :** ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

នរោត្តម សីហមុនី

៣រ.ល.០៧០៦.២៧១

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌលោក **ម៉ែន សាវុធ** ពីអនុមន្ត្រីថ្នាក់លេខ **៦** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ទៅជាអនុមន្ត្រីថ្នាក់លេខ **៦** នៃក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលនៅក្រសួងផែនការ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

៣.ល.០៧០៦.២៧២

លេខៈ ៤៦០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេង**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៤៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០០ ស្តីពីបុព្វសិទ្ធិរបស់បុគ្គលិក និងសមាជិកនៃរាជបណ្ឌិតសភាកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តមបណ្ឌិត **ឆាយ អូន** ជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការថ្នាក់អភិបាលស្រុកចំនួន ០២រូប នៅខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១-លោក **សយ សុត** | ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ២ ពីអភិបាលស្រុកស៊ីធរកណ្តាល ទៅជាអភិបាលស្រុកកញ្ច្រៀច |
| ២-លោក **ស៊ាន ម៉ុន្ថា** | ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលស្រុកកញ្ច្រៀច ទៅជាអភិបាលស្រុកស៊ីធរកណ្តាល ។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

__ចម្លងជូន :__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឈួន ផានី** ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរងខេត្តមណ្ឌលគិរី ជំនួសឯកឧត្តម **សួរ ណាត** ដែលទៅទទួលភារកិច្ចថ្មី ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧៨ អនក្រ.បក

# អនុក្រឹត្យ

**ស្ដីពី**

## ការកែសម្រួលមុខតំណែង និងតែងតាំងមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលមុខតំណែងលោក សូ សុខខេង ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៤ ពីអគ្គនាយករងទី១ មកជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ។

មាត្រា ២ : ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការចំនួន ០២រូប នៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោក **ឡាយ ទេះអារិទ្ធ** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៥ ជាអគ្គនាយករង

២- លោក **ឌី សុគន្ធវាន** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៣ ជាប្រធាននាយកដ្ឋានកិច្ចការនយោបាយ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៧៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ម៉ានីយ៉ាស គេសនំរ** ប្រធានសមាគម សប្បុរសជន ទូរីង-កម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ និងបណ្ណាល័យ នៅសាលាបឋមសិក្សាព្រះទន្លេ ស្ថិតនៅក្នុងឃុំសង្ស័រ ស្រុកស្វាយទាប និងអគារសិក្សា ០១ខ្នងទៀត នៅអនុវិទ្យាល័យពោធិ៍ធំ ស្ថិតនៅក្នុងឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ចំណាយអស់ថវិកាចំនួន ៦៥.៥៣៦ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៉

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាចូលរួមជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តស្រក និងវត្តរអាងលើ ឃុំស្រក និងឃុំរអាង ស្រុកកំពង់សៀម និង សមិទ្ធផលជាច្រើនទៀត នៅក្នុងខេត្តកំពង់ចាម ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ភិក្ខុ | **អ៊ូន ទ័ចឌី** | គ្រូសូត្រស្តាំ | បច្ច័យ ចំនួន ១២.៩៥០ ដុល្លារ |
| ២-លោក | **ហ៊ាង ម្ងនំា** | សប្បុរសជន | ថវិកា ចំនួន ១២.៧៥០ ដុល្លារ |
| ៣-លោក | **ថាន ចាន់** | សប្បុរសជន | ថវិកា ចំនួន ១១.៩៥០ ដុល្លារ |
| ៤-លោក | **ជ័យ ស៊ីវ៉ាន់** | សប្បុរសជន | ថវិកា ចំនួន ១០.៧៥០ ដុល្លារ |
| ៥-លោក | **ម៉េង អ៊ីន** | សប្បុរសជន | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ៦-លោក | **សយ សុត** | សប្បុរសជន | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ៧-លោក | **ទិាន់ សុផល** | សប្បុរសជន | ថវិកា ចំនួន ១០.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកំពង់ចាម ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន ក្នុងការអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា និងសង្គម ដោយបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តស្រែក និងវត្តរអាងលើ ឃុំស្រែក និងឃុំរអាង ស្រុកកំពង់សៀម និង សមិទ្ធផលជាច្រើនទៀតនៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :**

-ឯកឧត្តម **ចាយ បូរិន** ទីប្រឹក្សាសម្តេច ហេង សំរិន ប្រធានរដ្ឋសភា ថវិកាចំនួន ១៤០.៧៧០ ដុល្លារ

**ខ.មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :**

-ឯកឧត្តម **នាយ សាវុធ** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានផ្នែកស៊ើបអង្កេត ប្រឆាំងអំពើពុករលួយ ថវិកាចំនួន ៥៥.៧០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកំពង់ចាម ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ប្រគេនភិក្ខុ **ជាន សុខសាន្ត** ដែលមានស្នាព្រះហស្តនិងគុណបំណាច់ធំៗជាច្រើន ក្នុងការអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា និងសង្គម ដោយបានបរិច្ចាគបច្ច័យ ចូលរួមជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តស្រែក និងវត្តរអាងលើ ឃុំស្រែក និងឃុំរអាង ស្រុកកំពង់សៀម និង សមិទ្ធផលជាច្រើនទៀតនៅក្នុងខេត្តកំពង់ចាម សរុបបច្ច័យចំនួន ៦៥.០០០ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកំពង់ចាម ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៤៧៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលសមាសភាព ក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍ ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤២ អនក្រ.តត ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

# ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានតែងតាំងលោក **ចារ់ រ័ត្ន** ជាសមាជិកក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា ជំនួសលោក វរសេនីយ៍ឯក **ហ៊ុន ចំនួនតារ៉ា** អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ដែលត្រូវទៅបំពេញភារកិច្ចនៅក្រសួងមហាផ្ទៃវិញ ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានសភាពាណិជ្ជកម្ម និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០១០ សហវ.ក្បក.ពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧

ថ្ងៃទី២៩ ខែមិថុនា ២០០៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

យោងតាមមាត្រា៣០ថ្មី ក្នុងមាត្រា៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ និង ប្រកាសលេខ៤៩២ សហវ.ប្រក.ពដ. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នៅតាមខេត្ត-ក្រុង និងរាជធានីភ្នំពេញឱ្យបានជ្រាបថា:

ដីធ្លីមិនបានប្រើប្រាស់ស្ថិតនៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។ ដូចមានចែងក្នុងមាត្រា៣០ថ្មី ក្នុងមាត្រា៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ក្នុងការគិតពន្ធ មិនត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន ១.២០០ ម៉ែត្រក្រឡាសំរាប់ដីមួយកន្លែងទៀតទេ ។

- ពន្ធនេះត្រូវបង់តាមអត្រា ២ ភាគរយ លើមូលដ្ឋានកំណត់ពន្ធ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ផ្អែកលើតំលៃទីផ្សារ តាមទីក្រុង និងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡាសំរាប់ឆ្នាំនីមួយៗ ។

- កម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នីមួយៗ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធចំនួនពីរច្បាប់ និងគណនាប្រាក់ពន្ធដោយខ្លួនឯង ទៅតាមគំរូលិខិតប្រកាសដែលនាយកដ្ឋានពន្ធដារផ្តល់ជូន ហើយត្រូវបង់ពន្ធឱ្យបានចប់សព្វគ្រប់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំសារពើពន្ធនីមួយៗ ជូនទៅសាខាពន្ធដារខេត្ត-ក្រុង ដែលដីធ្លីនោះស្ថិតនៅ ។ ក្នុងករណីដែលកម្មសិទ្ធិករមិនបានដាក់លិខិតប្រកាសបង់ពន្ធ ឬមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវរងការដាក់ទោសទណ្ឌតាមមាត្រា១១៦ និង១១៧នៃច្បាប់ស្តីពីសារ

ពើពន្ធ ។ ទន្ទឹមនឹងនេះផ្អែកតាមមាត្រា ១៣១ និងមាត្រា១៣៦នៃច្បាប់ដដែលខាងលើ កម្មសិទ្ធិករត្រូវទទួលរងពិន័យបង់ប្រាក់ពន្ធបន្ថែមស្មើនឹង១០ភាគរយ ២៥ភាគរយ និង៤០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសំរាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួន ប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា កម្មសិទ្ធិករនៃជីធ្លីមិនបានប្រើប្រាស់ទាំងអស់ ប្រាកដជាយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធ បានល្អប្រសើជាពុំខាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង " ដើម្បីជូនជ្រាប "
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  " ដើម្បីមុខការ "
- គ្រប់អង្គភាពពន្ធដារ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N°៦០៨ ឧរថ.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧

# ប្រ កា ស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៧៤៤/០៧ គ.វ.ក ចុះថ្ងៃទី២៩.០៥.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៨៩៤/០៧ គ.វ.ក ចុះថ្ងៃទី០៧.០៦.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សាន់នី អឹបភែរេល មេនញូហ្វេកឈើរីង ចុះថ្ងៃទី៣១.០៥.២០០៧

# ស ម្រេ ច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន សាន់នី អឹបភែរេល មេនញូហ្វេកឈើរីង ( SUNNY APPAREL MANUFACTURING CO., LTD.) តំណាងដោយ លោកស្រី SEE BEE KEE-សញ្ជាតិម៉ាឡេស៊ី អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A13045765 ចុះថ្ងៃទី០៩.០៧.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "**សាន់នី អឹបភែរេល មេនញូហ្វេកឈើរីង** (SUNNY APPAREL MANUFACTURING )" មានទីតាំងស្ថិតនៅ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: ក្រុមហ៊ុនត្រូវ រៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរសម្លៀកបំពាក់ " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ ៤៧២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២០.០៧.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន "វីនណឺ ហ្គាមេន ទី២" (WINNER GARMENTS No2) ត្រូវចាត់ទុក ជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន សាន់នី អីបកែរេល មេនញូហ្វេកឈឺរីង ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១១: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ១០ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
Nº ៦០៩ ឧរថ.ករ.ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៩៣៧ ពណ.ពកប.កន ចុះថ្ងៃទី១៤.១២.១៩៩៣ របស់ក្រសួងពាណិជ្ជកម្ម
- យោងពាក្យស្នើរបស់ក្រុមហ៊ុន គ ឈ ហ្សេស៊ិន សហគ្រាស ចុះថ្ងៃទី២៨.០៣.២០០៧

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន គ ឈ ហ្សេស៊ិន សហគ្រាស ( K C GECIN ENTERPRISES LTD.) តំណាងដោយ លោក គីម ឈាន សញ្ជាតិខ្មែរ អាយុ៧៩ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010132883 ចុះថ្ងៃទី២៤.១២.២០០១ **បង្កើតរោងចក្រ "ផលិតសសរគ្រឹះបេតុង" ដែលមានឈ្មោះថា " គ ឈ ហ្សេស៊ិន សហគ្រាស សាខាទី១** ( K C GECIN ENTERPRISES BRANCH Nº 1 )" មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ២ ឃុំព្រែកហូរ ស្រុកតាខ្មៅ និង ឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ៥.

ប្រការ២: ក្រុមហ៊ុនត្រូវអនុវត្ត និងគោរពឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "ផលិតសសរគ្រឹះបេតុង " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន គ ឈ ហ្សេស៊ីន សហគ្រាស ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកណ្តាល
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N° ៦១០ ឧរថ.គឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៦៩ ឧរថ.កឧ.លស ចុះថ្ងៃទី១០.០៣.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៩១២ ពណ.នគក ចុះថ្ងៃទី២៦.០៧.២០០៦ របស់ក្រសួងពាណិជ្ជកម្ម
- យោងពាក្យស្នើរបស់ក្រុមហ៊ុន (ខេមបូឌា) បាយអូ-ថេក ឌីវេឡុបមេន ចុះថ្ងៃទី២៩.០៥.២០០៧

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន (ខេមបូឌា) បាយអូ-ថេក ឌីវេឡុបមេន ((CAMBODIA) BIO-TECH DEVELOPMENT CO., LTD.) តំណាងដោយ កញ្ញា ពុង ហ៊ុយ សញ្ជាតិខ្មែរ អាយុ៣១ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010468201 ចុះថ្ងៃទី២៨.០៤.២០០៣ បង្កើតរោងចក្រ "ផលិតប្រេងជីវឥន្ធនៈ" ដែលមានឈ្មោះថា "(ខេមបូឌា) បាយអូ.ថេក ឌីវេឡុបមេន ((CAMBODIA) BIO-TECH DEVELOPMENT )" មានទីតាំងស្ថិតនៅក្នុងបរិវេណរោងចក្រកែវ អាគារលេខ ១៣-១៤ សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល ១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតប្រេងជីវឥន្ធនៈ" ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុន ត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន (ខេមបូឌា) បាយអូ-ថេក ឌីវេឡុបមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០១៣៣ សស.ស / ម.ភ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៧

# សារាចរណែនាំ
## រដ្ឋមន្ត្រីក្រសួងសុខាភិបាល
## ជំរាបមក

- លោក - ប្រធានមន្ទីរពេទ្យជាតិ - ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
- លោក - លោកស្រីប្រធានមន្ទីរសុខាភិបាលខេត្ត - ក្រុង

**កម្មវត្ថុ :** ការបង្កើនការលើកទឹកចិត្តចំពោះឆ្មប ដោយបង្កើនប្រាក់ឧបត្ថម្ភជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ ។

**យោង :** -ប្រកាសអន្តរក្រសួង លេខ ២៦៨ សហវ . ហកចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៧ ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ។

- ការប្រជុំរវាងឯកឧត្តម នុត សុខុម រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាមួយឯកឧត្តម ហង្ស ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៧ នៅទីស្តីការក្រសួងសុខាភិបាល ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបជូនលោក - លោកស្រីប្រធានជ្រាបថា ដើម្បីអនុវត្តការផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់នៅតាមមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ក្នុងគោលបំណងកាត់បន្ថយអត្រា មរណៈមាតា និងទារក ឱ្យបានថយចុះជាអតិបរមា ក្រសួងសុខាភិបាលសុំធ្វើការណែនាំ ទាក់ទងទៅនិងការ ប្រើប្រាស់ប្រាក់ឧបត្ថម្ភដូចតទៅ :

១ - ដើម្បីអនុវត្តការលើកទឹកចិត្តនេះឱ្យមានប្រសិទ្ធិភាព និងតម្លាភាព ប្រធានអង្គភាព :

- អនុវត្តការបែងចែកប្រាក់ឧបត្ថម្ភផ្អែកលើនិយមន័យរបស់ពាក្យ : ក្រុមឆ្មបសំរាលកូន ដែលមានសមាសភាពដូចតទៅ :

ក / ឆ្មបដែលមានសញ្ញាប័ត្រមធ្យម ឬ បឋម

ខ / គិលានុបដ្ឋាកយិកាមធ្យម ឬ បឋមដែលបានបណ្តុះបណ្តាលជំនាញសំរាលកូន ០៤ ខែ

គ / វេជ្ជបណ្ឌិត គ្រូពេទ្យដែលមានជំនាញក្នុងផ្នែកសេវាសម្ភព

-ត្រូវពិនិត្យ និងរៀបចំសារឡើងវិញការបែងចែកឆ្មបដែលមានសមត្ថភាពក្នុងការសំរាលកូន ដែលត្រូវបានតែងតាំងឱ្យទៅបំរើការងារនៅផ្នែកផ្សេងៗ មិនចំទិសដៅឱ្យមកបំរើ

ការងារនៅផ្នែកសម្ភពតាមលទ្ធភាពជាក់ស្តែង ។

២ - នៅតាមមន្ទីរពេទ្យជាតិ - មជ្ឈមណ្ឌលជាតិ - មន្ទីរពេទ្យបង្អែក :

- ករណីសំរាលកូនរស់ធម្មតា : ក្រុមឆ្មបសំរាលកូនទទួលបាន ៩០ %

ក្រុមការងារពាក់ព័ន្ធទទួលបាន ១០ %

- ករណីសំរាលកូនពិបាកដោយមានអន្តរាគមន៍ ប្រធានអង្គភាពសាមុីជាអ្នកសំរេចចាត់ចែងប្រាក់ឧបត្ថម្ភនេះឱ្យមានតម្លាភាព

៣ - នៅតាមមណ្ឌលសុខភាព - ប៉ុស្តិ៍សុខភាព :

- ករណីសំរាលកូនរស់ធម្មតា : -ក្រុមឆ្មបសំរាលត្រូវទទួលបាន ៩០ %

-ក្រុមការងារពាក់ព័ន្ធទទួលបាន ១០ %

- ករណីស្ត្រីដែលត្រូវបានបញ្ជូនមកមណ្ឌលសុខភាពដោយឆ្មបបុរាណ ឬដោយអ្នកគាំទ្រសុខភាពភូមិ : -ក្រុមឆ្មបសំរាលត្រូវទទួលបាន ៧០ %

-ក្រុមបញ្ជូនមក និងក្រុមការងារពាក់ព័ន្ធទទួលបាន ៣០ %

៤ - ដើម្បីរៀបចំសំរួលឯកសារឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុនិងរបាយការណ៍ចំនួនកូនកើតរស់ដែលបានសំរាលនៅមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក ត្រូវមានការចុះហត្ថលេខាទទួលថវិកា១០០% ដោយតំណាងក្រុមឆ្មប និងមានការឯកភាពពីប្រធានមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ ឬ ប្រធានមន្ទីរពេទ្យបង្អែក ។

ចំពោះមណ្ឌលសុខភាព ឬ ប៉ុស្តិ៍សុខភាព ត្រូវមានការចុះហត្ថលេខាទទួលថវិការ ១០០% ដោយតំណាងក្រុមឆ្មប និងមានការឯកភាពពីប្រធានមណ្ឌលសុខភាព ឬ ប្រធានប៉ុស្តិ៍ភាព និង ប្រធានឃុំ ឬ ចៅសង្កាត់ ។

- ត្រូវប្រើប្រាស់គំរូស្តង់ដាឯកសារបច្ចេកទេស ដែលបានភ្ជាប់មកជាមួយ ។

៥ - សារាចរណែនាំនេះនឹងមានការកែប្រែក្នុងករណីចាំបាច់ ។

សូមលោក - លោកស្រីប្រធាន អនុវត្តសារាចរណែនាំខាងលើនេះឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុត ។

សូមលោក - លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

<u>ចំលងជូន :</u> ៗ

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សាលាខេត្ត-ក្រុង
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- នាយកដ្ឋានមន្ទីរពេទ្យ (ដើម្បីជ្រាប)
- គណៈវិជ្ជាជីវៈទាំងអស់
- ឯកសារ-កាលប្បវត្តិ

វេជ្ជ. នុត-សុខុម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៤៤ ៣៧ ធទឧ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

## ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពី ការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បានឃើញសេចក្តីសម្រេចលេខ ១៦១ សសរ.ធទឧ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៦ ស្តីពី ការបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មការគ្រប់គ្រងធនធានខ្សាច់
- បានឃើញការចាំបាច់របស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

## ស ម្រេ ច

**ប្រការ ១ :**

ត្រូវបានបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រួមមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ម៉ិន ម៉ាន | អគ្គនាយកកិច្ចការបច្ចេកទេសក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២- ឯកឧត្តម | ស៊ិន ទុន្នី | អគ្គាធិការក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣- លោក | ចាន់ យុត្ថា | នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម | ហ៊ី ឆាទី | អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ៥- លោក | ឡុង ឆុង | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦- លោក | ម៉ៅ ហាក់ | ប្រធាននាយកដ្ឋានជលសាស្ត្រនិងការងារទន្លេ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |

៧- លោក **យស មុនីរ៉ាត់** ប្រធាននាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៨- លោកស្រី **ជូ សុខផារ៉ានី** ប្រធាននាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន សមាជិក

៩- លោក **មុយ មុនិន្ទ** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

១០- លោក **ជា សុខនី** នាយខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី សមាជិក

១១- លោក **សុខ សំរុន** មន្ត្រីនាយកដ្ឋានរៀបចំដែនដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

**ប្រការ ២ :**

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ចដូចតទៅ :

- ជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ទទួលរៀបចំផែនការការងារ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិករបស់ គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

**ប្រការ ៣ :**

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងឯកឧត្តម អស់លោក លោកស្រី ដែលមានឈ្មោះចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ល។.

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ០៦ ឆ្នាំ ២០០៧

**ប្រធាន**

**លឹម គានហោ**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី ✓
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្ត.......................

"ដើម្បីជូនជ្រាប"

- ដូចក្នុងប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ [illegible]/០៧ គ.ជ.ប. [illegible]

## សេចក្តីសម្រេច

## ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា ចេញពីមណ្ឌលខេត្ត ព្រៃវែង

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៩ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.២៣២/០៣ គ.ជ.ប. ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៥១៧/០៣ គ.ជ.ប. ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ ។
- យោងលិខិតលេខ ៦២១ លគ.គក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការសុំប្រកាសទទួលស្គាល់បេក្ខជនជាប់ឆ្នោតថ្មីរបស់គណបក្ស **ប្រជាជនកម្ពុជា** ។

## សម្រេច

**ប្រការ១** : លុបឈ្មោះ
១- ឯកឧត្តម **ឯក សំអុល** ភេទប្រុស អាយុ ៥៩ ឆ្នាំ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ
២- ឯកឧត្តម **ម៉ុម ស៊ីមុន** ភេទប្រុស អាយុ ៥៩ ឆ្នាំ បេក្ខជនតំណាងរាស្ត្រ
៣- ឯកឧត្តម **តូច សារ៉ាក់** ភេទប្រុស អាយុ ៦០ ឆ្នាំ បេក្ខជនតំណាងរាស្ត្រ និង
៤- ឯកឧត្តម **ខុត សារអាន** ភេទប្រុស អាយុ ៥៩ ឆ្នាំ បេក្ខជនតំណាងរាស្ត្រ
នៃគណបក្ស **ប្រជាជនកម្ពុជា** ចេញពីបញ្ជីបេក្ខជនជាប់ឆ្នោត និង បេក្ខជនឈរឈ្មោះទៅមណ្ឌលខេត្ត **ព្រៃវែង** ។

**ប្រការ២** : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣** : សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធានស្តីទី**

**ក្មុយ ទើត**

**ចម្លងជូនជ្រាប**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- បណ្ណសារដ្ឋានជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ២៦៦/០៧ គ.ជ.ប.ស.ស.រ

## សេចក្តីសម្រេច

## ស្តីពីការប្រកាសទទួលស្គាល់ឯកឧត្តម សុខ សាយ បេក្ខជនតំណាងរាស្ត្រពេញសិទ្ធិ លំដាប់ទី ១០ របស់គណបក្សប្រជាជនកម្ពុជា នៅមណ្ឌលខេត្ត ព្រៃវែង

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៩ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.២៣២/០៣ គ.ជ.ប. ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៥១៧/០៣ គ.ជ.ប. ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ ។
- យោងសេចក្តីសម្រេចលេខ ២៦៥/០៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រគណបក្ស**ប្រជាជនកម្ពុជា** ចេញពីមណ្ឌលខេត្ត **ព្រៃវែង** ។

## សម្រេច

**ប្រការ១ :** ទទួលស្គាល់ឯកឧត្តម **សុខ សាយ** ភេទប្រុស អាយុ ៥៩ ឆ្នាំ ជាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្ស **ប្រជាជនកម្ពុជា** មណ្ឌលខេត្ត **ព្រៃវែង** ។

**ប្រការ២ :** គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣ :** សេចក្តីសម្រេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធានស្តីទី**

**ក្លុយ_ទៀត**

**ចម្លងជូនទ្រាប**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- បណ្ណសារដ្ឋានជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៧៦៧/០៧ គ.ជ.ប .ស.ស.រ

## សេចក្ដីសម្រេច
## ស្ដីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ដ្រ គណបក្ស សម រង្ស៊ី ចេញពីមណ្ឌលក្រុង ភ្នំពេញ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៩ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញសេចក្ដីសម្រេចលេខ ០៥.៣០៧/០៣ គ.ជ.ប. ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្ដីសម្រេចលេខ ០៨.៥១៥/០៣ គ.ជ.ប. ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៣ ស្ដីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ដ្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រអាណត្តិទី ៣ ។
- បានឃើញសេចក្ដីសម្រេចលេខ ០២១ ស.ស.រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤ ស្ដីពីការលុបឈ្មោះសមាជិកចេញពីបញ្ជីគណបក្ស របស់គណបក្ស សម រង្ស៊ី ។
- បានឃើញសេចក្ដីសម្រេចលេខ ៧៩២.០៦/០៧ ស.ស.រ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧ ស្ដីពីការលុបឈ្មោះសមាជិកចេញពីបញ្ជីគណបក្ស របស់គណបក្ស សម រង្ស៊ី ។
- យោងលិខិតលេខ ១០៦.០៦/០៧ គសរ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៧ ស្ដីពីការសុំលុបឈ្មោះ និងទទួលស្គាល់បេក្ខជនតំណាងរាស្ដ្រជាប់ឆ្នោតគណបក្ស **សម រង្ស៊ី** មណ្ឌលក្រុង **ភ្នំពេញ** ។

## សម្រេច

**ប្រការ១ :** លុបឈ្មោះ ១- ឯកឧត្ដម **កែវ រ៉េមី** ភេទប្រុស អាយុ ៤០ ឆ្នាំ បេក្ខជនជាប់ឆ្នោតតំណាងរាស្ដ្រ
២- ឯកឧត្ដម **ម៉ៅ យ៉ុវ៉ាន់** ភេទប្រុស អាយុ ៤៥ ឆ្នាំ បេក្ខជនតំណាងរាស្ដ្រ
នៃគណបក្ស **សម រង្ស៊ី** ចេញពីបញ្ជីបេក្ខជនជាប់ឆ្នោត និង បេក្ខជនឈរឈ្មោះនៅមណ្ឌលក្រុង **ភ្នំពេញ** ។

**ប្រការ២ :** គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣ :** សេចក្ដីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧
**ប.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

ទិត្យ ស៊ីថា

**ចម្លងជូនទ្រាប**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា- រដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- បណ្ណសារដ្ឋានជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៤២៥/០៧ **គ.ជ.ប.ស.ស.វ**

## សេចក្តីសម្រេច
## ស្តីពីការប្រកាសទទួលស្គាល់ឯកឧត្តម នូ សុវត្ថិ បេក្ខជនតំណាងរាស្ត្របំពេញសិទ្ធិ លំដាប់ទី ០៨ របស់គណបក្ស សម រង្ស៊ី នៅមណ្ឌលក្រុង ភ្នំពេញ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៩ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៩ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.៣០៧/០៣ គ.ជ.ប. ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៩១៩/០៣ គ.ជ.ប. ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ ។
- យោងសេចក្តីសម្រេចលេខ ៤២៤/០៧ គ.ជ.ប.ស.ស.វ ចុះថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រគណបក្ស **សម រង្ស៊ី** ចេញពីមណ្ឌលក្រុង **ភ្នំពេញ** ។

## សម្រេច

**ប្រការ១ :** ទទួលស្គាល់ឯកឧត្តម **នូ សុវត្ថិ** ភេទ ប្រុស អាយុ ៤០ ឆ្នាំ ជាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្ស **សម រង្ស៊ី** មណ្ឌលក្រុង **ភ្នំពេញ** ។

**ប្រការ២ :** គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣ :** សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៧
**ឋ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

**អ៊ឹម សួស្តី**

**ចម្លងជូនជ្រាប**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- បណ្ណសារដ្ឋានជាតិ
- គណបក្សនយោបាយ "ដើម្បីជូនជ្រាប"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ០៦១០ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **កែវ ថា អ៊ីមផត អិចផត & ឌីវេឡុបមេន (ខេ.ធី.អេ)**
**KEO THA IMPORT EXPORT & DEVELOPMENT (K.T.A) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9575/ 07P ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **កែវ ថា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ០១ ភូមិ ១ ឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្ត កំពត ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ និហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ
ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែក ហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

កឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសៅកុំព្យូទ័រ ✓
- សាលាខេត្តកំពត
- មន្ទីរពាណិជ្ជកម្មខេត្តកំពត "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៦១៧ ពណ.នតគ

ភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៧

# នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តាវ សាន អេនធើប្រាយ**
**TAO SAN ENTERPRISE CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9584/07P** ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **លីន ឈីងហុ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៦E០ ផ្លូវលេខ ៦៣ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការផ្គត់ផ្គង់សំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារធ្វើជូនអតិថិជនក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
- សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម-ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០១១៣ ពណ.ឧតគ

ភ្នំពេញថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០០៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឈាង ហួត**
CHHEANG HOUT Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9587/07P ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧
មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ហួត សុម៉ាលីស**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៤ ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -បណ្ណាគារ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
